ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន


លេខៈ ០៣០/ក.ប.ក អ.ជ.ប.គ.ញ
១៦

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៦ និងទិសដៅការងារ ខែឧសភា ឆ្នាំ២០១៦

( ពីថ្ងៃទី២៦/០៣/២០១៦ - ២៥/០៤/២០១៦ )

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ២០១៦កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈ ការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែមេសានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែមេសាឆ្នាំ២០១៦នេះ គ្រឿងញៀននៅតែបន្តធ្វើសកម្មភាពចរាចរឆ្លងកាត់ប្រទេសកម្ពុជា ដោយក្រុមឧក្រិដ្ឋជន ទាំងនៅក្នុងតំបន់ និងអន្តរជាតិ ។ តាមការកត់សម្គាល់គឺ ៖

- តាមផ្លូវគោក បណ្តាញក្រុមឧក្រិដ្ឋជនគ្រឿងញៀននៅក្នុងតំបន់ នៅតែបន្តនាំគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់ប្រទេសឡាវ ចូលមកកម្ពុជាតាមបណ្តាច្រករបៀងព្រំដែនរបស់ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ។ ជាក់ស្តែង សមត្ថកិច្ចនគរបាល និងសមត្ថកិច្ចកងរាជអាវុធហត្ថ បានបង្រ្កាប និងចាប់យកប្រភេទគ្រឿងញៀនសំយោគ ATS និង ហេរ៉ូអ៊ីន ស្មើនឹងជាង ៩០ % នៃចំនួនសរុប ដែលបានចាប់យកនៅក្នុងខែនេះ ព្រមទាំងឃាត់ខ្លួនជនសង្ស័យជាជនជាតិឡាវ ចំនួន ០៣ នាក់ ( ប្រុស )
- នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បណ្តាញក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ដែលធ្វើសកម្មភាពដោយស្ត្រីជនជាតិថៃ[1] បាននាំ កូកាអ៊ីន ពីប្រទេស BAHRAIN ឆ្លងកាត់ប្រទេស QATAR តាមជើងយន្តហោះ ចូលមកកម្ពុជា ដោយលាក់ក្នុងកំប៉ុងស្ករសូកូឡា ម៉ាក LINDOR និងប្រអប់ស្រាវីស្គី់ម៉ាក CONNEMARA ។

## II. អំពីការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗសម្រាប់អនុវត្តនៅក្នុងខែមេសានេះ ក៏ដូចជាបណ្តាខែខាងមុខមាន ដូចតទៅ ៖

---

1) ស្ត្រីជនជាតិថៃឈ្មោះ KAEWKANLAYA AMPHAWAN កាន់លិខិតឆ្លងដែនលេខ AA 5812431 ធ្វើដំណើរតាមជើងយន្តហោះ QR 970 ( ដូហា-ភ្នំពេញ )




អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

១. **ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ក្រៅពីការអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមសហគមន៍ ត្រូវយកចិត្តទុកដាក់អប់រំដល់បុគ្គលិក កម្មករនៅតាមរោងចក្រ សហគ្រាស និងពលករដែលត្រៀមទៅធ្វើការនៅក្រៅប្រទេស ព្រមទាំងបង្កើនលើការងារបណ្តុះបណ្តាលក្រុមជនបង្គោល ដើម្បីជួយដល់ការងារនេះ ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវរៀបចំកម្មវិធីសំណេះសំណាល និងសួរសុខទុក្ខអ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅក្នុងមណ្ឌលបណ្តោះអាសន្នរបស់កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ និងមណ្ឌលជីវិតថ្មីភ្នំបាក់, ក្រសួងសុខាភិបាលត្រូវគិតគូររៀបចំបង្កើតមណ្ឌលសុខភាពនៅក្នុងមណ្ឌលឱកាសខ្ញុំ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពិភាក្សាជាមួយក្រសួង-ស្ថាប័ននានា ពាក់ព័ន្ធនឹងការព្យាបាលពិរុទ្ធជន-ទណ្ឌិត ដែលញៀនគ្រឿងញៀននៅតាមមន្ទីរអប់រំកែប្រែនិងពន្ធនាគារ និងពង្រឹងគុណភាពសមត្ថភាពនៃការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមសហគមន៍ ។

៣. **ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) និងពង្រឹងយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤. **ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវរៀបចំផែនការ និងយន្តការដាក់លាក់សម្រាប់គ្រប់គ្រង ត្រួតពិនិត្យតាមដានលើការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ និងបន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៥. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន និងបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមក ។

៦. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** ត្រូវបន្តអនុវត្តនូវរាល់កិច្ចព្រមព្រៀងនានា ជាអាទិ អនុស្សរណៈនៃការយោគយល់គ្នាក្នុងមហាអនុតំបន់ទន្លេមេគង្គឆ្នាំ១៩៩៣, ការបន្តអនុវត្តផែនការ ៣ ឆ្នាំ សម្រាប់គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project), គម្រោងពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែនតាមដងទន្លេមេគង្គ (Mekong Project) របស់សាធារណរដ្ឋកូរ៉េ ។

៧. **ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវធ្វើការបូកសរុប ដកពិសោធន៍ ពីលទ្ធផលដែលបានចុះជួយពង្រឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

តាមប្រសាសន៍ណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ និងទិសដៅដែលបានដាក់ចេញកាលពីខែមីនា អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**-ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំ និងអញ្ជើញតំណាង

អធិការដ្ឋាននគរបាលក្រុងចំនួន ២ ដើម្បីចូលរួមផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី គឺ ៖

- អធិការដ្ឋាននគរបាលក្រុងតាខ្មៅ ខេត្តកណ្តាល ដើម្បីផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃ ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រក្រុងតាខ្មៅ (ថ្ងៃ២៧/៤/២០១៦)
- អធិការដ្ឋាននគរបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដើម្បីផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែត ស្តីពីការបង្ការ បង្ក្រាប និងដោះស្រាយរាល់បញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រក្រុងច្បារមន ខេត្តកំពង់ស្ពឺ (ថ្ងៃទី២៧ /៤/២០១៦) ។

**-ការងារអប់រំតាមសហគមន៍ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៧ បានចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមមូលដ្ឋានរបស់ខ្លួន (ឈ្មោះខេត្ត និងវេទិកានានាដែលបានធ្វើសកម្មភាពបញ្ជ្រាបខ្លឹមសារអប់រំមាននៅក្នុងតារាងឧបសម្ព័ន្ធទី១) ។ លទ្ធផលជារួម មហាជនដែលបានទៅទទួលសារអប់រំមានប្រមាណ **៨១៥.០៦៦** នាក់ ។ ក្នុងនោះ សកម្មភាពការងារអប់រំ ដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តមានដូចខាងក្រោម ៖

១. បានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើការអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកអង្គរជ័យ ខេត្តកំពត (មហាជនចូលរួមប្រមាណ ៣៥០ នាក់) និងនៅស្រុកបាទី, ក្រុងដូនកែវ ខេត្តតាកែវ (មហាជនចូលរួមប្រមាណ ៧៥០ នាក់) ។

២. បានរៀបចំពិធីអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅខេត្តកោះកុង កាលពីថ្ងៃទី០២-០៣ ខែមេសា ឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ (មហាជនចូលរួមប្រមាណ ២.០០០ នាក់) ។

៣. បានសហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការងារអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ។

៤. បានសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍រដ្ឋ-ឯកជន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងវិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន តាមរយៈការផ្សាយពាណិជ្ជកម្ម នៅតាមបណ្តាខេត្តនានា ។

៥. បាន និងកំពុងបន្តដំណើរការផលិតផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀន សម្រាប់ដាក់នៅតាមតំបន់ព្រំដែន កម្ពុជា-ឡាវ ។

៦. បាន និងកំពុងបន្តការចលនាដល់អង្គការ សមាគម និងវិស័យឯកជន ឱ្យចូលរួម និងគាំទ្រលើការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

៧. បាន និងកំពុងសហការអនុវត្តការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនដល់កម្មករ កម្មការនីនៅតាមរោងចក្រ សហគ្រាស និងពលករដែលត្រៀមទៅធ្វើការនៅបរទេស ។

៨. តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមីនា ឆ្នាំ២០១៦ មានការចូលអានប្រមាណ **៤៦.២៧០** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

២.១.១. បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងវាយតម្លៃគម្រោងប្រយុទ្ធនឹងមេ

រោគអេដស៍សម្រាប់សកម្មភាពនៅកម្ពុជា កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ តាមការអញ្ជើញរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ។

២.១.២. បានអនុញ្ញាតឱ្យអង្គការកសាង បន្តអនុវត្តកម្មវិធីម្ជុល/ស៊ីរាំង ក្នុងរាជធានីភ្នំពេញ ។

## ២.២. ការព្យាបាល និងស្តារនីតិសម្បទា

**-ការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមណ្ឌលបណ្តោះអាសន្ន ៖**

១. បានរៀបចំកម្មវិធីជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ អញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខអ្នកញៀនគ្រឿងញៀននៅមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់កងរាជអាវុធហត្ថ និងមណ្ឌលជីវិតថ្មីភ្នំបាក់ នៅខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពចូលរួមពីគ្រប់ក្រសួង-ស្ថប័នពាក់ព័ន្ធ ពិសេសពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ដើម្បីសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ និងបង្កើតមណ្ឌលស្តារនីតិសម្បទា នៅក្នុងរាជធានី-ខេត្ត រៀងៗខ្លួន ។

២. បាន និងកំពុងបន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំបង្កើតប៉ុស្តិ៍សុខភាព នៅក្នុងមណ្ឌលឱកាសខ្ញុំ ដើម្បីសម្រួលដល់ការផ្តល់សេវាសុខភាពដល់អ្នកញៀនគ្រឿងញៀន ។

៣. បានចូលរួមប្រជុំគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ នៅក្រសួងសុខាភិបាល ដើម្បីពិនិត្យលើរបាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន, ពិនិត្យលទ្ធភាពនៃការព្យាបាលទណ្ឌិត-ពិរុទ្ធជននៅក្នុងពន្ធនាគារដែលញៀនគ្រឿងញៀន និងពង្រឹងយន្តការការងារព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទា (មន្ត្រីសរុប ២៥ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប) ។

៤. បាននិងកំពុងរៀបចំរបាយការណ៍វាយតម្លៃពីឱសថ បុងសែន ដែលបានប្រើប្រាស់ក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្តោះអាសន្ន (រៀបចំដោយក្រសួងសុខាភិបាល) ។

៥. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានប្រគល់ម៉ាស៊ីនដេរ ចំនួន ១៨ គ្រឿង និងម៉ាស៊ីនផុងចំនួន ០២ គ្រឿង ដល់មណ្ឌលឱកាសខ្ញុំ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ។

**-ការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ៖**

១. មន្ទីរសុខាភិបាលរាជធានី-ខេត្ត បានបន្តធ្វើសកម្មភាពចលនា និងលើកទឹកចិត្តអ្នកប្រើប្រាស់គ្រឿងញៀនឱ្យស្ម័គ្រចិត្ត និងចេញទៅទទួលយកការព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក តាមរយៈការបញ្ជ្រាបលខ្លឹមសារផ្សព្វផ្សាយទៅក្នុងសកម្មភាពផ្សព្វផ្សាយផ្នែកសុខភាពផ្សេងៗ ។

២. មន្ទីរសុខាភិបាលរាជធានីភ្នំពេញ បានបន្តចុះពិនិត្យ និងពង្រឹងសមត្ថភាពមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារព្យបាលអ្នកញៀនគ្រឿងញៀន ។

៣. គណៈកម្មាធិការទទួលបន្ទុការងារព្យបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បាននិងកំពុងបន្តការរៀបចំយន្តការគាំទ្រ ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើសមាហរណកម្ម តាមរយៈផ្តល់ការបណ្តុះបណ្តាលបំណិនជីវិត និងវិជ្ជាជីវៈជំនាញផ្សេងៗ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៣.១.១. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ ១២ រូប ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី២/ឆ្នាំ២០១៦ ពីថ្ងៃទី០៤-០៨ ខែមេសា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

៣.១.២. បានចូលរួមកិច្ចប្រជុំ ពិភាក្សា ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីតុលាការ និងនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទ័ណ្ឌ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ នៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

៣.១.៣. បានចាត់មន្ត្រីចំនួន ០២ រូប (អគ្គស្នងការដ្ឋាននគរបាលជាតិ ០១ រូប, អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងអំពើរត់ពន្ធលុយ និងការងារត្រួតពិនិត្យឆ្លងកាត់ព្រំដែន ពីថ្ងៃទី១៨-២១ ខែមេសា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ។

៣.១.៤. បានបន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងពេលវេលា ការចេញ-ចូល របស់មុខសញ្ញាចរាចរ ជួញដូរគ្រឿងញៀនជាជនបរទេស ។

៣.១.៥. បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន ដែលជាគម្រោងគាំទ្រដោយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ចាប់ពីថ្ងៃទី២៥ខែមេសា ដល់ថ្ងៃទី០៤ខែឧសភាឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ មានសិក្ខាកាមចូលរួម ១០ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៥ នាក់)

៣.១.៦. បានចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ចំនួន ២៣ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៤ រូប) ទៅចូលរួមសិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ ពីថ្ងៃទី៣០ ខែមីនា ដល់ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ នៅខេត្តឈុនបុរី ប្រទេសថៃ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** សរុប **៣២៩** ករណី លើ ៣២១ ករណី នៃខែមីនា ឆ្នាំ២០១៦
- **ជនសង្ស័យ** ឃាត់ខ្លួន សរុប **៧៦៩** នាក់ (ស្រី ៩០ នាក់) លើ ៧៥៧ នាក់ នៃខែមីនា ឆ្នាំ២០១៦
- ក្នុងបទល្មើសគ្រឿងញៀនទាំង ៣២៩ ករណី និងជនសង្ស័យទាំង ៧៦៩ នាក់ ខាងលើគឺ ៖
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចនគរបាល** **២៤២** ករណី, ជនសង្ស័យ **៤៨៦** នាក់ (ស្រី ៤៩ នាក់)
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ** **៨៧** ករណី, ជនសង្ស័យ **២៨៣** នាក់ (ស្រី ៤១ នាក់)

- ក្នុងចំនួនជនសង្ស័យ ៧៦៩ នាក់ ខាងលើមាន ០៥ សញ្ជាតិគឺ ខ្មែរ ៧៥៤ នាក់ (ស្រី ៨៩ នាក់), វៀតណាម ០៩ នាក់ (ប្រុស), ថៃ ០១ នាក់ (ស្រី), ឡាវ ០៣ នាក់ (ប្រុស), ចិន ០២ នាក់ (ប្រុស), ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

- **វត្ថុតាងគ្រឿងញៀនចាប់យក** ៖ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៥.៦៩០ ក្រាម ៦០, មេតំហ្វេតាមីនគ្រាប់ WY ៧២២.៥៤ ក្រាម, ហេរ៉ូអ៊ីន ២.១៥៣,៩០ ក្រាម, កូកាអ៊ីន ២៥៤៩,៥១ ក្រាម, កេតាមីន ៣,៦៤ ក្រាម, ដើមកញ្ឆា ៣៥១ ដើម

- ទ្រព្យសម្បត្តិសំខាន់ៗ ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន ៖ រថយន្ត ៤ គ្រឿង ម៉ូតូ ១៦៣ គ្រឿង ប្រាក់កម្ពុជា ២.៤៨៣.៩០០ រៀល ប្រាក់ថៃ ៨.៦៧០ បាត ប្រាក់អាមេរិក ២.៦៦៧ ដុល្លារ , ប្រាក់វៀតណាម ៩៣.០០០ ដុង, ប្រាក់ចិន ១០០ យ៉ុន (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)

- ជនសង្ស័យចាប់តាមដីកា មាន ១០ ដីកា = ជនសង្ស័យ ១០ នាក់ (ប្រុសជនជាតិខ្មែរ)

### ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀនដែលបានធ្វើកោសល្យវិច័យក្នុង ខែមេសា ឆ្នាំ២០១៦ សរុប ២១៩ ករណី = ២៤៤ សំណាក ក្នុងនោះ ៖

- **សំណាក វិជ្ជមានសារធាតុញៀន** មាន ២១៨ ករណី = ២៣៩ សំណាក (៩៧,៩១ %)គឺ ៖
  - មេតំហ្វេតាមីន ICE ២១០ សំណាក = ៨៦,០៦ %
  - មេតំហ្វេតាមីន WY ១៨ សំណាក = ៧,៣៧ % - ហេរ៉ូអ៊ីន ០៣ សំណាក = ១,២២ %
  - កេតាមីន ០៥ សំណាក = ២,០៤ % - MDMA ០៣ សំណាក = ១,២២ %
- **សំណាក អវិជ្ជមានសារធាតុញៀន** ០១ ករណី = ០៥ សំណាក (២,០៤ %)

- បានផ្តល់ជូននូវតេស្តរកសារធាតុញៀនក្នុងទឹកនោមដល់ អគ្គស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង, មណ្ឌលគិរី, រតនគិរី, ក្រចេះ, កណ្តាល, ព្រះវិហារ, សៀមរាប, ឧត្តរមានជ័យ, បន្ទាយមានជ័យ, បាត់ដំបង, កំពត, កែប, ព្រះសីហនុ, កោះកុង, តាកែវ, ស្វាយរៀង, ព្រៃវែង, កំពង់ធំ សរុបចំនួន ២.៩២០ តេស្ត ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

ក្នុងខែមេសាឆ្នាំ២០១៦នេះ ទិន្នន័យសារធាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានអនុញ្ញាតឱ្យនាំចូល សរុបមាន **៧៥៥.២៦៥** គ.ក្រ ក្នុងនោះ ៖

- មានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន ៧០៥.២១៥ គ.ក្រ
- មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ៥០.០០០ គ.ក្រ
- មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុធាតុដើម ៥០ គ.ក្រ

ដោយឡែក សារធាតុញៀនពាក់ព័ន្ធនឹងតារាងទី II, III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាននៅក្នុងតារាងឧបសម្ព័ន្ធទី៣ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. បានចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៦ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

៥.២. បានដាក់បញ្ចូលគម្រោងផែនការស្នើសុំជំនួយកសាងមជ្ឈមណ្ឌលជាតិស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកជាសះស្បើយពីអាការញៀន ទៅក្នុងផែនការគម្រោងស្នើសុំជំនួយទ្វេភាគីពីរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

៥.៣. បានបន្តរៀបចំឯកសារចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បាន និងកំពុងរៀបចំឯកសារសម្រាប់ទៅចូលរួមវគ្គបណ្តុះបណ្តាល នៅបណ្ឌិត្យសភាអនុវត្តច្បាប់អន្តរ

ជាតិ (ILEA) នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ ។

៦.២. បាន និងកំពុងរៀបចំឯកសារនានា សម្រាប់ការចូលរួមកិច្ចប្រជុំ លើកទី២ លើគម្រោងការងារ ASOD ដើម្បីការពារសហគមន៍អាស៊ានប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ (២០១៦-២០២៥) ។

៦.៣. បានរៀបចំឯកសារពាក់ព័ន្ធនានា ដើម្បីទទួលជួបមន្ត្រីរបស់ការិយាល័យអគ្គរដ្ឋអាជ្ញាកូរ៉េ ១ រូប ដែលមកបំពេញបេសកកម្មនៅកម្ពុជា ពីថ្ងៃទី២៤ ខែមេសា ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ ។

៦.៤. បានត្រៀមពិធីចុះហត្ថលេខាលើឯកសារកម្មវិធីត្រួតពិនិត្យកុងតឺន័ររបស់អង្គការ UNODC អនុតំបន់។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានប្រមូលផ្តុំកម្លាំង ចុះទៅពង្រឹងការអនុវត្តបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់គ្រប់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ។

៧.២. បានសហការជាមួយក្រសួងមហាផ្ទៃ ចុះពង្រឹងកិច្ចការគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតាមរាជធានី-ខេត្ត ។

៧.៣. បានចូលរួមក្នុងសន្និបាតផ្សព្វផ្សាយសភាពការណ៍ កិច្ចប្រតិបត្តិការប្រឆាំងបទល្មើសគ្រឿងញៀនឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ។

៧.៤. បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៥. បាននិងកំពុងបន្តរៀបចំឡើងវិញនូវ សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.៦. បាននិងកំពុងបន្តការរៀបចំលិខិតបទដ្ឋានមួយចំនួន ដើម្បីបំពេញឱ្យអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៦

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. ត្រៀមចូលរួមធ្វើបទបង្ហាញស្តីពីបញ្ហាគ្រឿងញៀន នៅក្នុងវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងវិស័យទេសចរណ៍ និងយេនឌ័រ នៅរាជធានីភ្នំពេញថ្ងៃទី០៣/៥/២០១៦ និងនៅខេត្តកំពត ថ្ងៃទី១៨/៥/២០១៦ ។

១.២. ត្រៀមសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះទៅផ្សព្វផ្សាយច្បាប់, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកកោះធំ ខេត្តកណ្តាល ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ។

១.៣. ត្រៀមចូលរួមធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅវិទ្យាស្ថានសុខាភិបាល ក្រសួងការពារជាតិ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ។

១.៤. ត្រៀមអនុវត្តសាកល្បងនូវសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមរោងចក្រ សហគ្រាស ចំនួន ៧ នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុ ពីថ្ងៃទី០៩

ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៦ ។

១.៥. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៦. បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងបណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មនានា ។

១.៧. បន្តចលនាដល់អង្គការ សមាគម និងវិស័យឯកជន ឱ្យចូលរួម និងគាំទ្រលើការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៨. បន្តសហការជាមួយក្រសួងទេសចរណ៍ក្នុងការ ៖

- បញ្ជ្រាបខ្លឹមសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលពីគ្រឿងញៀននៅក្នុងយុទ្ធនាការប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ
- ចែកខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀននៅតាមគោលដៅទេសចរណ៍ ។

១.៩. បន្តជំរុញក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការផ្សព្វផ្សាយអប់រំដល់កម្មករ កម្មការនីនៅតាមរោងចក្រ សហគ្រាស និងពលករត្រៀមទៅធ្វើការនៅក្រៅប្រទេស និងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមរោងចក្រ និងសហគ្រាស ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

២.១. សហការជាមួយក្រសួងសុខាភិបាល ពិនិត្យលើសកម្មភាពក្នុងការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំងកន្លងមករបស់អង្គការ កសាង ដើម្បីវាយតម្លៃ និងផ្តល់ការគាំទ្រឱ្យបន្តការអនុវត្តកម្មវិធីនេះសម្រាប់ឆ្នាំ២០១៦-២០១៧ ។

២.២. ត្រៀមទៅចូលរួមវគ្គបណ្តុះបណ្តាលសាកល្បងលើការព្យាបាល និងថែទាំអ្នកញៀនគ្រឿងញៀន តាមសហគមន៍នៅតំបន់អាស៊ីអាគ្នេយ៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១០-១២ ខែឧសភា ឆ្នាំ២០១៦ នៅប្រទេសចិន ។

២.៣. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ដែលនៅជិត ។

២.៤. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៥. បន្តការរៀបចំបង្កើតប៉ុស្តិ៍សុខភាពនៅក្នុងមណ្ឌលឱកាសខ្ញុំ ។

២.៦. បន្តជំរុញមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ចុះពិនិត្យនិងពង្រឹងសមត្ថភាពមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារព្យាបាលអ្នកញៀនគ្រឿងញៀន ។

២.៧. បន្តរៀបចំយន្តការគាំទ្រ ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើសមាហរណកម្ម តាមរយៈផ្តល់ការបណ្តុះបណ្តាលបំណិនជីវិត និងវិជ្ជាជីវៈជំនាញផ្សេងៗ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

៣.១. បន្តបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ១២ រូប ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៣/២០១៦ ពីថ្ងៃទី០២-០៦ ខែឧសភា ឆ្នាំ២០១៦ ។

៣.២. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែនតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) ។

៣.៣. ត្រៀមសហការជាមួយក្រសួងការពារជាតិ រៀបចំវគ្គបណ្តុះបណ្តាលការទប់ស្កាត់ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដល់មន្ត្រីយោធាតំបន់ប្រតិបត្តិការសឹករង ចំនួន ៧, សាលានាយទាហាន ចំនួន ២, ទីបញ្ជាការដ្ឋានចំណុះឱ្យកងទ័ពជើងគោក និងជើងទឹក ចំនួន ២ (សម្រាប់ឆ្នាំ២០១៦) ។

៣.៤. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋាន ដល់មន្ត្រីពន្ធនាគារនៅតាមរាជធានី-ខេត្ត ។

៣.៥. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ០១ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល នៅបណ្ឌិត្យសភាអនុវត្តច្បាប់អន្តរជាតិ (International Law Enforcement Academies. ILEA) ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៣.៦. ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ ។

៤.២. ត្រៀមរៀបចំសេចក្តីព្រាងបទបញ្ញត្តិស្តីពី ការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម (ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម) ។

៤.៣. បន្តប្រមូលព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. បន្តអនុវត្តគម្រោងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥-២០១៦ ជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

៥.២. ត្រៀមទទួលមន្ត្រីព័ត៌មានវិទ្យា (Information of Technology. IT) របស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីពិភាក្សាក្នុងការរៀបចំបង្កើត Tele - Video Conference នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

៥.៣. ត្រៀមពិធីទទួលសម្ភារជំនួយរបស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)។

៥.៤. ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសវៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមទៅចូលរួមកិច្ចប្រជុំ លើកទី២ លើគម្រោងការងារ ASOD ដើម្បីការពារសហគមន៍អាស៊ានប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ សម្រាប់ឆ្នាំ២០១៦-២០២៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៧-១៨ ខែឧសភា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៦.២. ត្រៀមចូលរួមសន្និសីទថ្នាក់តំបន់ លើកទី២ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព្រំដែននៅអាស៊ាន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៦.៣. ត្រៀមទទួលតេស្តវិភាគគ្រឿងញៀនពីគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC)។

៦.៤. បន្តសហការជាមួយអង្គការ UNODC ចុះទៅពិនិត្យស្ថានភាពភូមិសាស្ត្រនៅច្រកថ្មដា ស្រុកវាលវែង (ខេត្តពោធិ៍សាត់), ច្រកទ្វារអន្តរជាតិអូរយ៉ាដាវ (ខេត្តរតនគិរី) និង ច្រកអានសេះ (ខេត្តព្រះវិហារ) ដើម្បីពិនិត្យ

លទ្ធភាពក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. បន្តពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀនដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៅរាជធានី-ខេត្តមួយចំនួនដែលនៅសេសសល់ ដើម្បីរៀបចំរបាយការណ៍បូកសរុប ដកពិសោធន៍ ពាក់ព័ន្ធនឹងលទ្ធផលនៃការចុះពង្រឹងការអនុវត្តបទបញ្ជានេះ ជូនរាជរដ្ឋាភិបាល ។

៧.២. បន្តអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៣. ត្រៀមចូលរួមសន្និបាតបូកសរុបការងារយុត្តិធម៌ ឆ្នាំ២០១៥ និងលើកទិសដៅការងារ ឆ្នាំ២០១៦ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ។

៧.៤. រៀបចំសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ ។

៧.៥. បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៦. រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**ឧត្តមសេនីយ៍ឯក.លី_គីមឡុង**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.៣
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣

  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.៣
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីមុខការ "
- ឯកសារ